ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy

លេខ: ០៧៤ រ៉ែ.អ.ខស.ហស.ណ ថ្ងៃពុធ ១រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២០.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុនដើម្បីធ្វើអាជីវកម្មដីល្បាយខ្សាច់ ក្នុងភូមិសាស្ត្រខេត្តកោះកុង និងខេត្តព្រះសីហនុ

ក្រសួងរ៉ែនិងថាមពលសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា៖ ក្រសួងរ៉ែនិងថាមពល នឹងដាក់ឱ្យមានការប្រកួតប្រជែងជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុនធ្វើអាជីវកម្មដីល្បាយខ្សាច់នៅទីតាំងចំនួន ៧ទីតាំង ក្នុងនោះភូមិសាស្ត្រខេត្តកោះកុង ចំនួន៣ទីតាំង និងខេត្តព្រះសីហនុ ចំនួន៤ទីតាំង ដូចមានផែនទីទីតាំង និងនិយាមកាជូនភ្ជាប់មកជាមួយដូចខាងក្រោម៖

ទីតាំងទី១៖ ស្ថិតនៅឃុំតានូន ស្រុកបូទុមសាគរ ខេត្តកោះកុង មានទំហំ ១០៩ហិកតា

ទីតាំងទី២៖ ស្ថិតនៅឃុំអណ្តូងទឹក និងឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង មានទំហំ ៨៩២ហិកតា

ទីតាំងទី៣៖ ស្ថិតនៅឃុំដងពែង ឃុំជីខក្រោម និងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង មានទំហំ ៤៦៤ហិកតា

ទីតាំងទី៤៖ ស្ថិតនៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មានទំហំ ៣១៨,៧០ហិកតា

ទីតាំងទី៥៖ ស្ថិតនៅឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មានទំហំ ៩១,៥០ហិកតា

ទីតាំងទី៦៖ ស្ថិតនៅឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ ៦០ហិកតា

ទីតាំងទី៧៖ ស្ថិតនៅឃុំរាម និងឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ ២២៨ហិកតា

ក្រុមហ៊ុនដែលមានបំណងចង់ចូលរួមប្រកួតប្រជែងនៅទីតាំងខាងលើ អាចចាត់តំណាងស្របច្បាប់ ឬប្រធានក្រុមហ៊ុនមកទទួលពាក្យ និងចុះឈ្មោះចូលរួមប្រកួតប្រជែងនៅនាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់ អគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល អគារលេខ ៧៩-៨៩ វិថីប៉ាស្ទ័រ (ផ្លូវលេខ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ នៅរៀងរាល់ម៉ោងធ្វើការ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ដែលមានការបញ្ជាក់ត្រឹមត្រូវ)។ ចំពោះអ្នកតំណាង ត្រូវមានសិទ្ធិប្រទានពីប្រធានក្រុមហ៊ុន។

ក្រុមហ៊ុនមួយអាចទទួលពាក្យស្នើសុំច្រើនទីតាំងបាន ប៉ុន្តែក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចទទួលយកឯកសារប្រកួតប្រជែងបានតែមួយគត់សម្រាប់មួយទីតាំង។

ក្រុមហ៊ុនដែលទទួលបានពាក្យស្នើសុំត្រូវមកចូលរួមប្រជុំស្តាប់ការណែនាំអំពីនីតិវិធីប្រកួតប្រជែង នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង៩:៣០នាទីព្រឹក នៅសាលប្រជុំអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល អាសយដ្ឋានអគារលេខ១៣, ១៤ មហាវិថីសហព័ន្ធរុស្ស៊ី(១១០) រាជធានីភ្នំពេញ។

ស៊ុយ_សែម

សូមទាក់ទងទូរស័ព្ទលេខ៖

១-លោក ជួន សុខជា 016 651155

២-លោក រៀង វណ្ណារិទ្ធ 012 966 464

៣-លោក តឹក តុប 088 888 7088

# ទីតាំងទី១
## ស្ថិតនៅឃុំតាអូន ស្រុកបទុមសាគរ ខេត្តកោះកុង មានទំហំ១០៩ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|
| DS1 | 310737 | 1207650 |
| DS2 | 312460 | 1207650 |
| DS3 | 312460 | 1207020 |
| DS4 | 310737 | 1207020 |

# ទីតាំងទី២

## ស្ថិតនៅឃុំអណ្ដូងទឹក និងឃុំកណ្ដោល ស្រុកបទុមសាគរ ខេត្តកោះកុង មានទំហំ៨៨២ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|
| BS1 | 334091 | 1231984 |
| BS2 | 337119 | 1234191 |
| BS3 | 339308 | 1234670 |
| BS4 | 340078 | 1233626 |
| BS5 | 334707 | 1231026 |

# ទីតាំងទី៣

## ស្ថិតនៅឃុំដងពែក ឃុំជីខក្រោម និងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង មានទំហំ៤៦៤ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|
| SA1 | 350961 | 1225415 |
| SA2 | 353161 | 1223945 |
| SA3 | 351097 | 1221296 |
| SA4 | 350240 | 1221900 |
| SA5 | 351866 | 1223964 |
| SA6 | 350503 | 1224821 |

# ទីតាំងទី៤

## ស្ថិតនៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មានទំហំ៣១៨.៧ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|
| A | 352735 | 1205882 |
| B | 354316 | 1205877 |
| C | 354930 | 1204134 |
| D | 352915 | 1204089 |



Datum: WGS 1984 UTM Zone 48N

N

**កំណត់សម្គាល់៖**

ទីតាំងទី៤

# ទីតាំងទី៥

## ស្ថិតនៅឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មានទំហំ ៨១,៥ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|
| A | 352281 | 1188577 |
| B | 353229 | 1189155 |
| C | 353805 | 1188596 |
| D | 352834 | 1188081 |

0 0.5 1 2 3 4 Kilometers



N

Datum: WGS 1984 UTM Zone 48N

**កំណត់សម្គាល់៖**

ទីតាំងទី៥

# ទីតាំងទី៦

## ស្ថិតនៅឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ៦0ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|
| A | 362114 | 1161682 |
| B | 362219 | 1161687 |
| C | 362313 | 1161034 |
| D | 362065 | 1160142 |
| E | 361596 | 1159505 |
| F | 361291 | 1159710 |
| G | 361757 | 1160286 |
| H | 362117 | 1161049 |



Datum: WGS 1984 UTM Zone 48N

N

**កំណត់សម្គាល់៖**

ទីតាំងទី៦

# ទីតាំងទី៧
## ស្ថិតនៅឃុំរាម និងឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ២២៨ហិកតា




| ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|
| A | 362588 | 1163833 |
| B | 362627 | 1164235 |
| C | 365215 | 1163846 |
| D | 367261 | 1163188 |
| E | 368450 | 1162410 |
| F | 368314 | 1162042 |
| G | 367154 | 1162820 |
| H | 365185 | 1163483 |